# គ្មានកន្លែងសម្រាប់ខ្មាំងសត្រូវនៃព្រលឹងខ្ញុំទៀតឡើយ

*អែលឌើរដែប្រ៊ី អ័រ ហ្វឡែន*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ក្នុងពេលថ្មីៗនេះ នៅពេល ស៊ិស្ទើរ ហ្វឡែន និងខ្ញុំបានចុះពីយន្តហោះនៅព្រលានយន្តហោះក្នុងទីក្រុងដាច់ស្រយាល មួយ ស្រាប់តែមាននារីស្រស់ស្អាតបីរូប ដែលជិះយន្តហោះជើងជាមួយនឹងពួកយើងប្រញាប់ប្រញាល់មករាក់ទាក់ពួកយើង។ ពួកគេប្រាប់ថាពួកគេជាសមាជិកនៃសាសនាចក្រ ដែលយើងមិនសូវភ្ញាក់ផ្អើលទេ ព្រោះថាអ្នកដែលមិនមានជំនឿដូចយើង ជាធម្មតាមិនប្រញាប់មករកយើង នៅព្រលានយន្តហោះនោះទេ។ នៅក្នុងការសន្ទនា ដែលយើងមិនបានរំពឹងទុក ភ្លាមនោះយើងបានដឹងតាមរយៈទឹកភ្នែករបស់ពួកគេថា នារីទាំងបីនាក់នោះ ទើបតែបានលែងលះនឹងប្តី នៅក្នុងករណីនីមួយៗ គឺដោយសារតែប្តី មិនស្មោះត្រង់នឹងពួកគេ ហើយប្រភពនៃករណីដែលការបែកបាក់គ្នា និងអំពើរំលងបានចាប់ផ្តើមឡើងដោយការជាប់ចិត្ត ទៅនឹងរូបអាសគ្រាម។

ព្រមជាមួយនឹងការណែនាំមិនរីករាយចំពោះសារលិខិតរបស់ខ្ញុំនៅថ្ងៃនេះ ខ្ញុំមានអារម្មណ៍ដូចជាយ៉ាកុប ពីបុរាណ ដែលបាននិយាយថា "ហើយវាក៏ធ្វើឱ្យខ្ញុំកើតទុក្ខ ដែលខ្ញុំត្រូវប្រើពាក្យដ៏ធ្ងន់ធ្ងរដល់អ្នក នៅចំពោះ[មនុស្ស] ដែលភាគច្រើនមានអារម្មណ៍ទន់ភ្លន់ និងបរិសុទ្ធ និងចិត្តទោទន់។ 1 ប៉ុន្តែយើងចាំបាច់ត្រូវប្រើពាក្យធ្ងន់ធ្ងរ។ ប្រហែលជា នោះមកពីខ្ញុំគឺជាឪពុក ឬអាចជាជីតា ប៉ុន្តែទឹកភ្នែកនៅក្នុងកែវភ្នែករបស់ស្ត្រីក្មេងទាំងនោះ បាននាំឱ្យខ្ញុំទឹកភ្នែក ហើយសំណួរទាំងឡាយដែលពួកគេសួរបានធ្វើឱ្យខ្ញុំងឿងឆ្ងល់ថា--- តើហេតុអ្វីបានជាមានការពុករលួយខាងសីលធម៌ ច្រើនយ៉ាងនេះនៅជុំវិញខ្លួនយើង ហើយតើហេតុអ្វីបានជាបុគ្គលម្នាក់ៗ និងគ្រួសារជាច្រើន ធ្លាក់រងគ្រោះទៅក្នុងវា ហើយស្ថិតនៅក្នុងភាពភ័យខ្លាចយ៉ាងសោកនាដកម្មដោយសារវាដូច្នេះ?

ប្រាកដណាស់ ខ្ញុំបានដឹងចម្លើយខ្លះៗចំពោះសំណួររបស់ខ្ញុំ។ ស្ទើរតែរាល់ថ្ងៃយើងទាំង អស់គ្នាឃើញ ថាខ្លួនយើង--- ត្រូវបានឈ្លានពាន ដោយសារលិខិតអសីលធម៌មួយចំនួន ដែលលិចមកលើយើងពីគ្រប់ជ្រុងជ្រោយ។ ផ្នែកខ្មៅងងឹតរបស់ឧស្សាហកម្មខ្សែភាពយន្ត ទូរទស្សន៍ និងតន្ត្រី បានបោះជំហានកាន់តែឆ្ងាយទៅៗ នៅក្នុងភាពខ្មៅក្រខ្វក់ ផ្សព្វផ្សាយនៅក្នុងសង្គម ព្រមជាមួយនឹងសំដីអាក្រក់ និងការប្រព្រឹត្តខុសខាងផ្លូវភេទ។ គួរឲ្យខ្លាចផង សេវាកម្មកុំព្យូទ័រ និងអ៊ិនធើរណែតដដែល ដែលអនុញ្ញាតឱ្យខ្ញុំធ្វើពង្សប្រវត្តិរបស់ខ្ញុំ ហើយរៀបចំឈ្មោះទាំងនោះសម្រាប់កិច្ចការក្នុងព្រះវិហារបរិសុទ្ធ អាចអនុញ្ញាតឱ្យកូន ឬចៅៗរបស់ខ្ញុំ ចូលទៅក្នុងលូទឹកស្អុយនៃរូបភាពនិងគំនិតជាសាកល ដែលអាចបំផ្លាញគំនិតរបស់ពួកគេយ៉ាងអាក្រក់ជារៀងរហូត ដោយគ្មានតម្រង និងការគ្រប់គ្រង។

សូមចងចាំថា ភរិយាវ័យក្មេងទាំងនោះ បាននិយាយថា ភាពមិនស្មោះត្រង់របស់ស្វាមីរបស់ពួកគេបានចាប់ផ្ដើមមកពីការជាប់ចិត្តនឹងរូបអាសគ្រាម ប៉ុន្តែសកម្មភាពអសីលធម៌មិនមែនគ្រាន់តែជាបញ្ហារបស់បុរសទេ ហើយស្វាមីមិនមែនជាអ្នកដែលធ្វើអំពើរំលងតែម្នាក់ឯងប៉ុណ្ណោះនោះដែរ។ គ្រោះថ្នាក់កើតមានមកពីការចុចលើកូនកណ្ដុរ--- រួមមានទាំងអ្វីដែលអាចកើតឡើង នៅក្នុងការនិយាយលេងជាមួយនឹងអ្នកផ្សេងទៀតតាមបន្ទប់អ៊ិនធើរណែត--- ដែលស្វាគមន៍មនុស្សគ្រប់ជំពូក ទាំងបុរស ឬស្ត្រី ក្មេងឬចាស់ អ្នករៀបការ ឬអ្នកនៅលីវផងដែរ។ ហើយដើម្បី ប្រាកដថា ការល្បួងនោះ មានកាន់តែច្រើន មាសត្រូវកំពុងរវល់ពង្រីកទំហំរបស់វាទៅតាមទូរស័ព្ទ ល្បែងវីដេអូ និង iPod ។

បើសិនជាយើងឈប់កាប់ចិញ្ច្រាំមែកធាងនៃបញ្ហានេះ ហើយកាប់ឱ្យឫសគល់នៃដើមឈើនេះ នោះវាមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលយើងនឹងរកឃើញតណ្ហា ដែលជាឫសគល់នៃបញ្ហា។ តណ្ហា គឺជាពាក្យទោមនស្ស ហើយច្បាស់ណាស់ថា វាគឺជាប្រធានបទទោមនស្សដើម្បីនិយាយ ប៉ុន្តែមានមូលហេតុល្អ ដែលទំនៀមទំលាប់មួយចំនួនស្គាល់វាថាជាសេចក្ដីអំពើបាបដ៏សាហាវបំផុត នៃ «អំពើបាបដែលបណ្ដាលឱ្យស្លាប់ប្រាំពីរប្រការ»។ 2

តើហេតុអ្វីបានជាតណ្ហា គឺជាអំពើបាប "បណ្ដាលឱ្យស្លាប់"? ក្រៅ ពីគ្រោះថ្នាក់ខាងព្រលឹងវិញ្ញាណរបស់យើង ដោយការបណ្ដេញព្រះវិញ្ញាណចេញទាំងស្រុងនោះ ខ្ញុំគិតថាវាគឺជាអំពើបាបមួយ ពីព្រោះធ្វើឲ្យកខ្វក់ដល់ទំនាក់ទំនងដ៏ខ្ពស់បំផុត និងពិសិដ្ឋបំផុត ដែលព្រះបានប្រទានឱ្យនៅក្នុងជីវិតរមែងស្លាប់នេះ--- ជាសេចក្ដីស្រឡាញ់ ដែលបុរស និងនារីម្នាក់ មានចំពោះគ្នាទៅវិញទៅមក ហើយបំណងប្រាថ្នារបស់គូស្វាមីភរិយានោះ ដើម្បីនាំកូនចៅមកនៅក្នុងគ្រួសារ ដោយមានបំណងចង់នៅជាមួយគ្នា ជារៀងរហូត។ មានមនុស្សម្នាក់ បាននិយាយថា សេចក្ដីស្រឡាញ់ពិត ត្រូវតែមានរួមនូវគំនិត នៃភាពជានិច្ចកាល។ សេចក្ដីស្រឡាញ់ពិត ជាការប្រកាន់ខ្ជាប់។ ប៉ុន្តែ មិនថាបុរស ឬស្ត្រីទេ តណ្ហាផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនៅពេលវា អាចបើកទៅទំព័ររូបអាសគ្រាម ឬក្រឡេកមើលទៅមនុស្សដទៃទៀត ដែលផ្ដោតទៅលើតណ្ហាពេលដើរជិត។ ចំពោះសេចក្ដីស្រឡាញ់ពិត យើងពិតជាមានចិត្តរំភើបណាស់ --- ដូចជារូបខ្ញុំចំពោះស៊ិស្ទើហូឡែន ដូច្នោះដែរ យើងស្រែកប្រកាសអំពីសេចក្ដីស្រឡាញ់ពិតពីលើដំបូលផ្ទះ។ ប៉ុន្តែតណ្ហា ត្រូវបានចង្អុលពីលក្ខណៈ សេចក្ដីអាម៉ាស់ និងការលាក់លៀម ហើយត្រូវបានចង្អុលពីលក្ខណៈថា វាជំរុញឱ្យមានការលាក់បំពួន ពីមនុស្សដទៃដែលស្ទើរតែពុំអាចគ្រប់គ្រងបាន--- កាលណាកាន់តែយប់ ហើយកាន់តែងងឹត គឺកាន់តែល្អ រួចមានទ្វារសោពីរទុកត្រៀម។ សេចក្ដីស្រឡាញ់ ធ្វើឱ្យយើងឈោង ទៅរកព្រះ និងអ្នកដទៃដោយស្វ័យប្រវត្តិ។ ផ្ទុយទៅវិញ តណ្ហា គឺមិនមកពីព្រះទេ ហើយជាការផ្ដោតគិតសប្បាយតែខ្លួនឯង។ សេចក្ដីស្រឡាញ់បណ្ដាលឱ្យយើងមានសេចក្ដីសប្បុរស និងការទទួលយកដោយសេចក្ដីស្រឡាញ់ ប៉ុន្តែតណ្ហាកើតមកជាមួយនឹងភាពស្រេកឃ្លានដោយបើកចំហរតែប៉ុណ្ណោះ។

ទាំងនេះគឺជាមូលហេតុមួយចំនួន ដែលធ្វើឱ្យពុករលួយដល់អត្ថន័យពិតនៃសេចក្ដីស្រឡាញ់--- មិនថានៅក្នុងការនឹកគិតរបស់យើង ឬជាមួយមនុស្សដទៃទេ--- វាគឺជាការបំផ្លាញយ៉ាងខ្លាំង។ វាបំផ្លាញនូវអ្វីដែលសំខាន់ជិតស្មើនឹងសេចក្ដីជំនឿរបស់យើងទៅលើព្រះ គឺជា ការទុកចិត្តនៅក្នុងខ្លួនមនុស្សទាំងឡាយ ដែលយើងស្រឡាញ់។ វាធ្វើឱ្យគ្រឹះនៃការទុកចិត្ត ដែលសេចក្ដីស្រឡាញ់មាននាពេលបច្ចុប្បន្ន--- ឬពេលអនាគត--- ទន់ខ្សោយ ហើយវាចំណាយពេលយ៉ាងយូរ ដើម្បីស្ថាបនាឡើងវិញនូវការទុកចិត្ត ដែលវាបានបាត់បង់ទៅហើយនោះ។ បើបញ្ហានេះអាក្រក់ខ្លាំង មិនថាជាលក្ខណៈផ្ទាល់ខ្លួន ក៏ដូចជាសមាជិកគ្រួសារ ឬជាសាធារណៈដូចជា មន្ត្រីរជំរើស ពួកអ្នកដឹកនាំអាជីវកម្ម តួរកុន ឬជើងឯកកីឡាក្តី មិនយូរមិនឆាប់សង្គមនឹងឈប់មានគ្រឹះនៃការទទួលខុសត្រូវខាងសីលធម៌ទៀតហើយ។

ទាំងអ្នកនៅលីវ ឬអ្នករៀបការរួច ទាំងក្មេង ឬចាស់ ចូរងាកមកនិយាយមួយសន្ទុះអំពីរបៀបដើម្បីទប់ទល់នឹងការល្បួងគ្រប់ប្រភេទ មិនថាវាមានរូបរាងយ៉ាងណាទេ។យើងមិនអាចព្យាបាលជម្ងឺសង្គមទាំងអស់បានទេ ប៉ុន្តែចូរនិយាយអំពី សកម្មភាពផ្ទាល់ខ្លួនមួយចំនួន ដែលយើងអាចធ្វើបាន។

- ដំបូងគេ ចូរចាប់ផ្ដើមដោយការញែកខ្លួនរបស់អ្នកនៅឱ្យឆ្ងាយពីមនុស្ស សម្ភារ និងស្ថានភាពទាំងឡាយ ដែលនឹងធ្វើឲ្យអ្នកមានគ្រោះថ្នាក់។ ដូចជាអ្នកទាំងឡាយដែល កំពុងតែច្បាំងនឹងគ្រឿងស្រវឹងបានដឹងការទាក់ទាញឱ្យខិតទៅជិត អាចបណ្តាលឱ្យស្លាប់។ បញ្ហាសីលធម៌គឺមានសណ្ឋានដូចគ្នានេះផងដែរ។ ដូចជាលោកយ៉ូសែប នៅក្នុងវត្តមានរបស់ប្រពន្ធប៉ូទីផារផងដែរ [3] គឺគ្រាន់តែរត់ចេញ--- រត់ចេញឱ្យឆ្ងាយតាមដែលអ្នកអាចធ្វើទៅបាន ចេញពីអ្វី ឬនរណា ដែលល្បួងបញ្ឆោតអ្នក។ ហើយនៅពេលរត់គេចចេញពីរូបភាពកន្លែងនៃការល្បួង សូមកុំទុកអាសយដ្ឋានឲ្យវាតាមមករកទៀត។

- ត្រូវដឹងថា មនុស្សដែលត្រូវបានចងជាប់ដោយច្រវ៉ាក់នៃទម្លាប់ដ៏បំផ្លិចបំផ្លាញ ឬការញៀន ជាញឹកញាប់ត្រូវការជំនួយខ្លាំងជាងការជួយដោយខ្លួនឯង ហើយរឿងនោះ អាចរួមមានទាំងអ្នក។ ចូរស្វែងរកជំនួយនោះ ហើយស្វាគមន៍ចំពោះជំនួយនោះ។ និយាយជាមួយប៊ីស្សពរបស់អ្នក។ ធ្វើតាមដំបូន្មានរបស់គាត់។ សុំការប្រសិទ្ធពរបព្វជិតភាព។ ប្រើប្រាស់គេហទំព័រសាសនាចក្រថ្មីរបស់សាសនាចក្រ ចុះឈ្មោះក្នុងកម្មវិធីព្យាបាលការញៀនថ្នាំ ឬស្វែងរកជំនួយពីអ្នកជំនាញសមរម្យដទៃទៀត។ អធិស្ឋានសុំឲ្យឈប់។ សុំឲ្យពួកទេវតាមកពីទាំងសង្ខាងរាំងននឲ្យមកជួយអ្នក។

- ព្រមជាមួយនឹងតម្រងនៅក្នុងកុំព្យូទ័រ និងការចាក់សោចំពោះការជាប់ចិត្ត សូមចងចាំថា មានការគ្រប់គ្រងដ៏ពិតតែមួយគត់នៅក្នុងជីវិត គឺការគ្រប់គ្រងខ្លួនឯង។ ហាត់គ្រប់គ្រងលើខ្លួនអ្នកឲ្យបានច្រើន ទោះបីជាពេលធម្មតា ដែលនៅប្រឈមមុខនឹងអ្នកក្ដី។ បើសិនជាកម្មវិធីទូរទស្សន៍ មានរឿងមិនសមរម្យ បិទវាចោល។ បើសិនជាខ្សែភាពយន្ត មានលក្ខណៈថោកទាប ដើរចេញពីវា។ បើសិនជាមានទំនាក់ទំនងមិនត្រឹមត្រូវកើតឡើង ផ្តាច់វាចេញ។ ឥទ្ធិពលជាច្រើនទាំងនេះ មិនមែនជារឿងអាក្រក់ខាងបច្ចេកទេសទេ ប៉ុន្តែ

ពួកវាអាចធ្វើឱ្យយើងវេចវិលក្នុងការវិនិច្ឆ័យ វេចវិលខាងវិញ្ញាណរបស់យើង ហើយដឹកនាំទៅរកអ្វីដែលជារឿងអាក្រក់។ សុភាសិតពីបុរាណមួយបាននិយាយថា ការធ្វើដំណើររាប់ពាន់គីឡូ ចាប់ផ្ដើមដោយការបោះជំហានទីមួយ ដូច្នេះចូរមើលការបោះជំហានរបស់អ្នក។

ដូចជាចោរនៅពេលយប់ គំនិតមិនគប្បីអាចកើតមាន ហើយស្វែងរកច្រកផ្លូវចូលមកក្នុងគំនិតរបស់ចិត្ត។ ប៉ុន្តែយើងមិនត្រូវបើកទ្វារ បំរើទឹកតែ និងនាំស្រួយដល់វា ហើយប្រាប់កន្លែងដាក់គ្រឿងកំបិត ស្លាបព្រាសមទេ! (យ៉ាងណាក៏ដោយក៏អ្នកមិនគួរបំរើទឹកតែដែរ។) បោះគំនិតអាក្រក់ចេញ! ជំនួសគំនិតអាសគ្រាមដោយរូបភាពនៃក្ដី សង្ឃឹម និងអនុស្សាវរីយ៍រីករាយ រូបភាពទឹកមុខនៃមនុស្សទាំងឡាយដែលអ្នកស្រឡាញ់ ហើយបើអ្នកចុះចាញ់នោះវានឹងបែកខ្ចាយអស់។ មានបុរសជាច្រើន ត្រូវបានសង្គ្រោះពីអំពើបាប ឬភាពឆ្កួតលីលា ដោយការចងចាំទឹកមុខរបស់ម្ដាយ ប្រពន្ធ ឬកូនរបស់គាត់ ដែលកំពុងតែរង់ចាំគាត់នៅផ្ទះ។ មិនថាអ្នកមានគំនិតអ្វីទេ ត្រូវប្រាកដថាគំនិតទាំងនោះត្រូវបានស្វាគមន៍មកដួងចិត្តរបស់អ្នក «ដោយការអញ្ជើញតែប៉ុណ្ណោះ»។ ដូចជាកំណាព្យពីបុរាណមួយបាននិយាយថា ចូរឲ្យឆន្ទៈរបស់អ្នកធ្វើជាមូលហេតុរបស់អ្នក។[5]

- ត្រូវលើកកំពស់ និងស្ថិតនៅកន្លែងដែលព្រះវិញ្ញាណនៃព្រះអម្ចាស់គង់នៅ។ ត្រូវប្រាកដថាវាមាននៅក្នុងគេហដ្ឋាន ឬកន្លែងរស់នៅរបស់អ្នក ដោយគ្រប់គ្រងលើសិល្បៈ តន្ត្រី និងអក្សរសាស្ត្រ គ្រប់ប្រភេទដែលអ្នកមាននៅទីនោះ។ បើសិនជាអ្នកបានទទួលអំណោយទានពិសិដ្ឋរួចហើយ សូមទៅព្រះវិហារបរិសុទ្ធឱ្យបានញឹកញាប់ តាមដែលស្ថានភាពហុចឱ្យ។ ចូរចងចាំថា ព្រះវិហារបរិសុទ្ធ ការពារអ្នក «ដោយព្រះចេស្ដារបស់ [ព្រះ]... [ដាក់] សិរីល្អរបស់ទ្រង់... នៅជុំវិញ [អ្នក] ហើយ [មានទេវតា] របស់ទ្រង់ មើលថែទាំ [អ្នក]»។[6] នៅពេលអ្នកចាកចេញពីព្រះវិហារបរិសុទ្ធ សូមចងចាំអំពីនិមិត្តរូបដែលអ្នកយកមកជាមួយនឹងអ្នកមិនត្រូវទុកចោល ឬបំភ្លេចចោលឡើយ។

មនុស្សភាគច្រើនដែលស្ថិតក្នុងបញ្ហា នៅទីបំផុតស្រែកឡើងថា «តើខ្ញុំកំពុងតែគិតអ្វីហ្នឹង?» មែនហើយ មិនថាអ្វីក៏ដោយដែលពួកគេគិត ពួកគេមិនកំពុងតែគិតអំពីព្រះគ្រីស្ទទេ។ ប៉ុន្តែក្នុងនាមជាសមាជិកនៃសាសនាចក្រ យើងសន្យាជារៀងរាល់ថ្ងៃអាទិត្យ ក្នុងជីវិតរស់នៅរបស់យើង ដើម្បីលើកដាក់ព្រះនាមរបស់ទ្រង់មកលើខ្លួនយើង ហើយសន្យាថា «ចងចាំទ្រង់ជានិច្ច» [7] ដូច្នេះ សូមយើងខិតខំឱ្យខ្លាំងឡើងថែមទៀតក្នុងការរឭកចាំពីទ្រង់ ---ជាពិសេស ថាទ្រង់បាន «ប្រសូតមករងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើង... [ដែល]ទ្រង់ត្រូវវាយជាំដោយព្រោះអំពើទុច្ចរិតរបស់យើង... ហើយយើងរាល់គ្នាបានប្រោសឱ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់»។[8] ប្រាកដណាស់ថាវានឹងដឹកនាំសកម្មភាព របស់យើង នៅក្នុងរបៀបដ៏ល្អបំផុត បើយើងចងចាំថា គ្រប់ពេលដែលយើងធ្វើអំពើរំលង នោះយើងមិនត្រឹមតែធ្វើទុក្ខដល់អ្នកដែលយើងស្រឡាញ់ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ធ្វើទុក្ខដល់ទ្រង់ផងដែរ ដែលទ្រង់ស្រឡាញ់យើងយ៉ាងខ្លាំង។ ប៉ុន្តែបើសិនជាយើងធ្វើអំពើបាប មិនថាអំពើបាបនោះធ្ងន់ធ្ងរ

យ៉ាងណាទេ នោះយើងអាចត្រូវបានសង្គ្រោះ ដោយសារព្រះដ៏អស្ចារ្យដែលនេះ ទ្រង់មាននាមតែមួយគត់ដែលនៅក្រោមមេឃ ដើម្បីឱ្យមនុស្សប្រុស ឬស្រី គ្រប់រូបអាចត្រូវបានសង្គ្រោះ។[9] នៅពេលប្រឈមមុខនឹងអំពើរំលងរបស់យើង ហើយព្រលឹងរបស់យើង ត្រូវបានរងនូវការឈឺចាប់ដ៏ពិត នោះសូមឲ្យយើងទាំងអស់គ្នាអាចបន្លឺសម្លេងដែលអាលម៉ាបានបន្លឺឡើង ពេលផ្លាស់ប្ដូរជីវិតរបស់គាត់ថា «ឱព្រះយេស៊ូវអើយ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ សូមព្រះអង្គមានសេចក្ដីមេត្តាករុណាមកលើទូលបង្គំផង»។[10]

បងប្អូនប្រុសស្រី ខ្ញុំស្រឡាញ់អ្នករាល់គ្នា។ ប្រធានម៉នសុន និងបងប្អូនប្រុសទាំងឡាយ ស្រឡាញ់អ្នករាល់គ្នា។ ដែលសំខាន់ជាងនេះទៅទៀត ព្រះវរបិតាសួគ៌របស់អ្នកស្រឡាញ់អ្នករាល់គ្នា។ ខ្ញុំបានព្យាយាមនិយាយនៅទីនេះ អំពីក្ដីស្រឡាញ់-- គឺការគោរពវា ហើយអំពីការបង្ហាញ មានរូបភាពត្រឹមត្រូវអំពីប្រធានបទនេះនៅក្នុងសង្គមល្អៗដែលមនុស្សលោកបានស្គាល់អំពីសេចក្ដីបរិសុទ្ធនៃសេចក្ដីស្រឡាញ់ពិត រវាងបុរស និងស្ត្រីដែលរៀបការរួច ហើយនិងគ្រួសារ ដែលសេចក្ដីស្រឡាញ់នោះបង្កើតឡើងនៅទីបំផុត អំពីការបង្ហាញសេចក្ដីស្រឡាញ់ដ៏ប្រោសលោះ ជាតួអង្គច្បាស់លាស់ ដែលមកកាន់យើង តាមរយៈព្រះគុណរបស់ព្រះគ្រីស្ទផ្ទាល់។ ជាចាំបាច់ ខ្ញុំក៏បាននិយាយផងដែរអំពីអារក្សអេល ឌីយ៉ាប្លូ ជាមនុស្សកំណាចម្នាក់ ជាឪពុកនៃការកុហក និងតណ្ហា ដែលនឹងធ្វើអ្វីៗគ្រប់យ៉ាង ដែលវាអាចធ្វើដើម្បីក្លែង រឿងទាំងអស់នេះ ដើម្បីបន្ទាបបន្ថោក ឬប្រមាថដល់ក្ដីស្រឡាញ់ពិត នៅគ្រប់កន្លែងដែលវាជួបប្រទះ។ ហើយខ្ញុំបាននិយាយអំពីបំណងប្រាថ្នារបស់វា ក្នុងការបំផ្លាញ យើងតាមដំណើរការ បើវាអាចធ្វើ។

នៅពេលយើងប្រឈមមុខនឹងការល្បួងដូច្នេះ នៅក្នុងជំនាន់របស់យើង យើងត្រូវតែ ប្រកាសដូចជាយុវជននីហ្វៃបានធ្វើ៖ «[ខ្ញុំនឹង] មិនទុកកន្លែងសម្រាប់ខ្មាំងសត្រូវនៃព្រលឹងខ្ញុំទៀតឡើយ»។ 11 យើងអាចបដិសេធនឹងមនុស្សអាក្រក់។ បើសិនជាយើងពិតជាចង់ដោយអស់ពីដួងចិត្ត និងជ្រាលជ្រៅល្មមគ្រប់គ្រាន់ នោះសត្រូវអាច ហើយនឹងត្រូវបានស្ដីបន្ទោសដោយព្រះចេស្ដាដ៏ប្រោសលោះនៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ។ បន្ថែមពីលើនោះទៀត ខ្ញុំសូមសន្យានឹងអ្នករាល់គ្នាថា ពន្លឺនៃដំណឹងល្អដ៏អស់កល្បរបស់ទ្រង់ អាច ហើយនឹងបានភ្លឺចែងចាំជាថ្មីម្ដងទៀត នៅកន្លែងដែលអ្នកបានភ័យខ្លាចថា ជីវិតមានភាពងងឹតអស់សង្ឃឹម  និងគ្មានជំនួយនោះ។ សូមឱ្យសេចក្ដីអំណរចំពោះភក្ដីភាពរបស់យើង ចំពោះអ្វីដែលខ្ពស់បំផុត ហើយល្អបំផុតនៅក្នុងខ្លួនយើង មកជារបស់ផងយើង នៅពេលយើងរក្សាសេចក្ដីស្រឡាញ់ និងអាពាហ៍ពិពាហ៍ សង្គមនិងព្រលឹងរបស់យើងឲ្យបានបរិសុទ្ធ ដូចដែលគួរតែបានបរិសុទ្ធ ខ្ញុំអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. យ៉ាកុប 2:7។

2. សូមមើល ឧទាហរណ៍ Henry Fairlie´s excellent The Seven Deadly Sins Today ទំព័រ 1978។

3. សូមមើល Fairlie, Seven Deadly Sins ទំព័រ 175។

4.សូមមើល លោកុប្បត្តិ 39:1--13។

5. សូមមើល Juvenal's The Satires (VI, 223)។

6. គ. និងស. 109:22.

7. គ. និង ស. 20:77--79។

8. អេសាយ 53:4--5។

9. សូមមើល កិច្ចការ 4:12។

10. អាលម៉ា 36:18។

11.នីហ្វៃទី  2 4:28 បន្ថែមអក្សរទ្រេត។